# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ.................................. ស.ខ.ក.ក.

## សារលិខិតរំលែកទុក្ខ

**ជូន**

**លោក វិញ ថន ប្រធានគណៈកម្មការទ្រទ្រង់សហគមន៍ខ្មែរកម្ពុជាក្រោម**
**ប្រចាំតំបន់សាំងប៉ែកណាឌីណូ**

ក្នុងនាមសមាជិក សមាជិកាសហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់មានសេចក្ដីរន្ធត់ចិត្តក្ដុកក្ដួលយ៉ាងខ្លាំង បន្ទាប់ពីបានទទួលព័ត៌មានថា លោកស្រី **សឺន សារេត** បានទទួលមរណភាពកាលពីវេលាម៉ោង ១១:៤៥នាទីយប់ ថ្ងៃទី០២ តុលា ឆ្នាំ២០០៦ (ថ្ងៃនៅសហរដ្ឋអាមេរិក) កន្លងទៅនេះ ។

ខ្ញុំសូមចូលរួមរំលែកទុក្ខយ៉ាងសែនក្រៀមក្រំ និងសោកស្ដាយជាទីបំផុតជាមួយលោក **វិញ ថន** និងក្រុមគ្រួសារនៃសពទាំងអស់ ដែលកំពុងមានទុក្ខជាទម្ងន់ ដោយបានបាត់បង់សមាជិកគ្រួសារ ជាភរិយា ជាមាតា ជាយាយ គឺលោកស្រី **សឺន សារេត** ។

មរណភាពរបស់អ្នកស្រី **សឺន សារេត** គឺជាការបាត់បង់ស្ត្រីខ្មែរកម្ពុជាក្រោមដ៏ឆ្នើមមួយរូប ដែលធ្វើឲ្យសហគមន៍ខ្មែរកម្ពុជាក្រោមទាំងក្នុង និងក្រៅប្រទេសមានការសោកស្ដាយ អាល័យស្រណោះយ៉ាងក្រៃលែង ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមវាយតម្លៃយ៉ាងខ្ពស់បំផុតចំពោះវីរភាព និងគុណបំណាច់ដ៏ធំធេងរបស់អ្នកស្រី សឺន សារេត ដែលបានលះបង់គ្រប់បែបសព្វយ៉ាងក្នុងការចូលរួមចំណែកបំរើប្រទេសជាតិ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ ជាពិសេសអ្នកស្រីគឺជាភរិយាមួយរូបដ៏ល្អ ដែលបានជួយជំរុញ និងលើកទឹកចិត្តលោក **វិញ ថន** ដែលជាប្រធានគណៈកម្មការទ្រទ្រង់សហគមន៍ខ្មែរកម្ពុជាក្រោម ធ្វើសកម្មភាពដោយជោគជ័យក្នុងការដឹកនាំតំបន់សាំងប៉ែកណាឌីណូ ក្លាយទៅឈានមុខគេក្នុងការជួយឧបត្ថម្ភគាំទ្រដល់សកម្មភាពជាតិរបស់សហគមន៍ខ្មែរកម្ពុជាក្រោម ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងចងចាំជានិច្ចនូវគុណបំណាច់ដ៏ធំធេងរបស់អ្នកស្រី សឺន សារេត ដែលបានបំពេញកិច្ចការដ៏សំខាន់ទាំងនេះជូនប្រទេសជាតិ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ។

ដោយផលានិសង្ស ដែលបានបំពេញយ៉ាងច្រើនចំពោះជាតិ សាសនាខ្មែរកម្ពុជាក្រោម សូមឲ្យវិញ្ញាណក្ខ័ន្ធរបស់អ្នកស្រីបាននៅសោយសុខក្នុងសុខគតិភពកុំបីខានឡើយ ។

សូមលោក **វិញ ថន** និងក្រុមគ្រួសារទាំងអស់ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៦*

**ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**

**អតីតសមាជិកព្រឹទ្ធសភា**

ភូមិគ្រឹះលេខ៥៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៩៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.
អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org